**នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ៖ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក

ភាគីដាក់ឯកសារ៖ លោក **ខៀវ សំផន**

ដាក់ជូន៖ អង្គជំនុំជម្រះតុលាការកំពូល

ភាសាដើម៖ **បារាំង**

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៦

**ឯកសារបកប្រែ**
**TRANSLATION/TRADUCTION**
ថ្ងៃ ខែ ឆ្នាំ (Date): 24-Oct-2016, 12:14
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ៖ សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះសាលាដំបូង៖ **សាធារណៈ/Public**

ប្រភេទនៃចំណាត់ថ្នាក់៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន៖

ឈ្មោះមន្ត្រីទទួលបន្ទុកផ្នែកសំណុំរឿង និងឯកសារ៖

ហត្ថលេខា៖

---

**ចម្លើយតបរបស់មេធាវីការពារក្តី លោក ខៀវ សំផន ទៅនឹងបណ្តឹងសាទុក្ខឆ្លាមៗរបស់ដើមបណ្តឹងរដ្ឋប្បវេណី ពាក់ព័ន្ធនឹងអំពើរំលោភសេពសន្ថវៈក្រៅអាពាហ៍ពិពាហ៍**

---

<u>ដាក់ដោយ</u>៖

**មេធាវីការពារក្តី លោក ខៀវ សំផន**

មេធាវី គង់ សំអុន

មេធាវី Anta GUISSÉ

<u>ដាក់ជូន</u>៖

**អង្គជំនុំជម្រះតុលាការកំពូល៖**

ចៅក្រម គង់ ស្រ៊ីម

ចៅក្រម Agnieszka KLONOWIECKA-MILART

ចៅក្រម សោម សិរីវឌ្ឍ

ចៅក្រម Chandra Nihal JAYASINGHE

**ជំនួយការ៖**
លោកស្រី សេង សុជាតា
កញ្ញា Marie CAPOTORTO
កញ្ញា អ៊ូច ស្រីផាត
កញ្ញា Soumeya MEDJEBEUR
លោក Clément BOSSIS
កញ្ញា Cécile ROUBEIX
លោក តាន់ ឆាយរ័ត្ន

ចៅក្រម ម៉ុង មុន្នីចរិយា
ចៅក្រម Florence Ndepele MWACHANDE-MUMBA
ចៅក្រម យ៉ា ណារិន

**សហព្រះរាជអាជ្ញា៖**
លោកស្រី ជា លាង
លោក Nicholas KOUMJIAN

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់**

**ក្រុមមេធាវីការពារក្តី លោក នួន ជា**

# គោរពជូនអង្គជំនុំជម្រះតុលាការកំពូល

១. នៅថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០១៦ ភាគីបានទទួលសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខភ្លាមៗរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ("ដើមបណ្តឹងរដ្ឋប្បវេណី") ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ("អង្គជំនុំជម្រះ") លើសំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណីសុំឱ្យមានការបញ្ជាក់អំពីវិសាលភាពនៃការចោទប្រកាន់ ទាក់ទងនឹងអំពើរំលោភសេពសន្ថវៈក្រៅបរិបទនៃការរៀបអាពាហ៍ពិពាហ៍ ("បណ្តឹងសាទុក្ខ")[1]។

២. តាមរយៈសារណានេះ មេធាវីការពារក្តី លោក ខៀវ សំផន ("មេធាវីការពារក្តី") ស្នើសុំឱ្យអង្គជំនុំជម្រះតុលាការកំពូលមេត្តាសម្រេចថា បណ្តឹងសាទុក្ខនេះ មិនអាចទទួលយកបានទេ។

## I. ប្រវត្តិនីតិវិធី

៣. នៅថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០ សហចៅក្រមស៊ើបអង្កេត ("ស.ច.ស") បានចេញដីកាដំណោះស្រាយ នៅក្នុងសំណុំរឿង ០០២ ដែលក្នុងដីកានោះ ស.ច.ស បានសម្រេចបញ្ជូនជនត្រូវចោទទៅជំនុំជម្រះ ចំពោះអង្គហេតុមួយចំនួនធំ ដែលខ្លួនត្រូវបានស្នើសុំឱ្យពិនិត្យ[2]។ ប៉ុន្តែ ស.ច.ស បានធ្វើសេចក្តីសន្និដ្ឋានថា ពុំមានបន្ទុកគ្រប់គ្រាន់ប្រឆាំងនឹងជនត្រូវចោទ ទាក់ទងនឹងអំពើរំលោភសេពសន្ថវៈក្រៅបរិបទនៃការរៀបអាពាហ៍ពិពាហ៍ ("អំពើរំលោភក្រៅអាពាហ៍ពិពាហ៍")។ ហេតុដូច្នេះ ស.ច.ស បានសម្រេចមិនបញ្ជូនជនត្រូវចោទ ទៅជំនុំជម្រះ ចំពោះអង្គហេតុមួយនេះ[3]។

---

[1] បណ្តឹងសាទុក្ខភ្លាមៗរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ចំពោះសំណើសុំការបញ្ជាក់ពីវិសាលភាពទាក់ទងនឹងបទចោទនៃការរំលោភសេពសន្ថវៈ នៅក្រៅបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ចុះថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១៦ ឯកសារ **E306/7/3/1/1** ("បណ្តឹងសាទុក្ខ")។

[2] ដីកាដំណោះស្រាយ ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១១ ឯកសារ **D427**។

[3] ដីកាដំណោះស្រាយ កថាខណ្ឌ ១៥២៤, ១៥៤៥, ១៥៤៨, ១៥៥១, ១៥៥៤, ១៥៥៩ ព្រមទាំងកថាខណ្ឌ ១៤២៦-១៤២៩ និង កថាខណ្ឌ ៩២៦-៩២៧ និង ១១៨១ ផងដែរ។

៤. សហព្រះរាជអាជ្ញា ពុំបានប្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយឡើយ ដើម្បីជំទាស់នឹងសេចក្ដីសម្រេចរបស់ ស.ច.ស ទាក់ទងនឹងអំពើរំលោភក្រៅអាពាហ៍ពិពាហ៍។ ជនជាប់ចោទ បានប្ដឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្ដីសន្និដ្ឋានផ្សេងៗទៀត ដែលមាននៅក្នុងដីកាដំណោះស្រាយ។

៥. នៅថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ អង្គបុរេជំនុំជម្រះ បានចេញសេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍របស់ជនជាប់ចោទ ប្រឆាំងនឹងដីកាដំណោះស្រាយ តែអង្គបុរេមិនត្រូវបានស្នើសុំឲ្យពិនិត្យលើបញ្ហាការរំលោភក្រៅអាពាហ៍ពិពាហ៍ឡើយ[4]។ ដូច្នេះ ជនជាប់ចោទត្រូវបានបញ្ជូនទៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ដើម្បីកាត់សេចក្ដី ទាក់ទងនឹងអង្គហេតុទាំងឡាយ ដូចមានកំណត់នៅក្នុងដីកាដំណោះស្រាយ និងស្របតាមសេចក្ដីសម្រេចនានារបស់អង្គបុរេជំនុំជម្រះ។

៦. នៅថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០១១[5] ឆ្លើយតបទៅនឹងសារណារបស់សហព្រះរាជអាជ្ញា ដើមបណ្ដឹងរដ្ឋប្បវេណីដែល“*ធ្វើសេចក្ដីសន្និដ្ឋានថា សំអាងហេតុរបស់ ស.ច.ស ដែលពុំបានផ្ដន្ទាទោសជនជាប់ចោទចំពោះអំពើរំលោភសេពសន្ថវៈ ដែលស្ថិតនៅក្រៅបរិបទអាពាហ៍ពិពាហ៍ដោយបង្ខំ គឺមានភាពចន្លោះប្រហោង*”[6] បានស្នើសុំអង្គជំនុំជម្រះឲ្យ “កំណត់បទចោទសាជាថ្មី” ចំពោះអំពើរំលោភនេះ។ ក៏ប៉ុន្តែ ដើមបណ្ដឹងរដ្ឋប្បវេណីបានទទួលស្គាល់ថា “*ក.ស.ច.ស មិនបានចោទប្រកាន់ករណីទាំងនេះឡើយ*”[7]។

៧. នៅថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១៤ បីសប្ដាហ៍ក្រោយពីបានកំណត់វិសាលភាពសំណុំរឿង ០០២/

---

[4] សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ ឯកសារ **D427/4/14**, សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ និង នួន ជា ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ ឯកសារ **D427/2/12**, សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ ឯកសារ **D427/1/26**។

[5] ចម្លើយតបរបស់សហមេធាវីនាំមុខដើមបណ្ដឹងរដ្ឋប្បវេណី ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញា សុំឲ្យកំណត់បទចោទសាជាថ្មី ទាក់ទងនឹងអង្គហេតុនៃអំពើរំលោភសេពសន្ថវៈ ថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ចុះថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០១១ ឯកសារ **E99/1**។

[6] យោងដូចខាងលើ កថាខណ្ឌ ៤០ (យើងជាអ្នកគូសបន្ទាត់ពីក្រោម)។

[7] យោងដូចខាងលើ កថាខណ្ឌ ៣២ (យើងជាអ្នកគូសបន្ទាត់ពីក្រោម)។

០២ រួចមក[8] អង្គជំនុំជម្រះបានសម្រេចបដិសេធចោលសំណើនេះ ដោយយល់ឃើញថាជាសំណើសុំឱ្យមានការពង្រីកវិសាលភាពការចោទប្រកាន់ និងគ្មានមូលដ្ឋានគតិយុត្តត្រឹមត្រូវ[9]។

៨. នៅថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០១៥ អង្គជំនុំជម្រះ មិនត្រឹមតែបានរំឭកអំពីសេចក្ដីសម្រេចរបស់ខ្លួនកាលពីឆ្នាំ ២០១៤ ប៉ុណ្ណោះទេ តែថែមទាំងបាននិយាយឡើងវិញថា ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ជនជាប់ចោទ ចំពោះអំពើរំលោភសេពសន្ថវៈ ដែលបានកើតឡើង ជាពិសេសនៅមន្ទីរសន្តិសុខក្រាំងតាចាន់ ពុំត្រូវបានចោទប្រកាន់ឡើយ[10]។

៩. នៅថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១៦ ដើមបណ្ដឹងរដ្ឋប្បវេណី បានដាក់សំណើសុំ "ឱ្យមានការបញ្ជាក់អំពីវិសាលភាព [នៃសំណុំរឿង ០០២/០២] ទាក់ទងនឹងការចោទប្រកាន់អំពើរំលោភសេពសន្ថវៈដែលត្រូវបានប្រព្រឹត្តឡើងក្រៅបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ"។ ដើមបណ្ដឹងរដ្ឋប្បវេ-ណី លើកឡើងថា អង្គជំនុំជម្រះត្រូវបានស្នើសុំឱ្យពិនិត្យលើអំពើរំលោភក្រៅអាពាហ៍ពិពាហ៍ និងត្រូវសម្រេចលើបញ្ហានេះ ដោយពុំមានជាប់កាតព្វកិច្ចគោរពតាមការកំណត់បទចោទ ដែលត្រូវបានជ្រើសរើសដោយ ស.ច.ស នោះទេ ("សំណើសុំឱ្យបញ្ជាក់អំពីវិសាលភាពនៃសំណុំរឿង")[11]។

១០. នៅថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១៦ មេធាវីការពារក្ដី បានឆ្លើយតបថា អង្គជំនុំជម្រះមិនដែលធ្លាប់ត្រូវបានស្នើសុំឱ្យពិនិត្យលើអង្គហេតុមួយនេះទេ ហើយហេតុដូច្នេះ អង្គជំនុំជម្រះពុំអាចសម្រេចលើបញ្ហាមួយនេះ បាននោះទេ[12]។

---

[8] សេចក្ដីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមលើសំណុំរឿង ០០២ និងវិសាលភាពនៃសំណុំរឿង ០០២/០២ ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១៤ ឯកសារ **E301/9/1** ជាមួយឧបសម្ព័ន្ធ **E301/9/1.1**។

[9] ព័ត៌មានបន្ថែមទាក់ទងនឹងអញ្ញត្រកម្មដែលនៅសេសសល់ ចុះថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១៤ ឯកសារ **E306** កថាខណ្ឌ ៣។

[10] សេចក្ដីសម្រេចលើសំណើរបស់ ខៀវ សំផន សុំឱ្យមានការតទល់គ្នារវាងដើមបណ្ដឹងរដ្ឋប្បវេណី សយ សែន ជាមួយនឹងសាក្សី ស្រី ថន និងដើមបណ្ដឹងរដ្ឋប្បវេណី សូត្រ សាំង និងស្នើសុំឯកសារថតចម្លងនៃការស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី សយ សែន ចុះថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ **E348/4** កថាខណ្ឌ ១១។

[11] សារណារបស់សហមេធាវីនាំមុខដើមបណ្ដឹងរដ្ឋប្បវេណី អនុលោមតាមវិធាន ៩២ នៃវិធានផ្ទៃក្នុង ស្ដីពីការបញ្ជាក់ពីវិសាលភាពនៃសំណុំរឿង ០០២/០២ ទាក់ទងនឹងបទចោទនៃការរំលោភសេពសន្ថវៈ នៅក្រៅបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ចុះថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ **E306/7** ("សំណើសុំឱ្យបញ្ជាក់អំពីវិសាលភាពនៃសំណុំរឿង")។

[12] ចម្លើយតបរបស់មេធាវីការពារក្ដីលោក ខៀវ សំផន ទៅនឹងសំណើសុំបំភ្លឺរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ពាក់ព័ន្ធនឹងបទចោទនៃ

១១. នៅថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១៦ ដើមបណ្តឹងរដ្ឋប្បវេណី បានឆ្លើយតបទៅនឹងចម្លើយតបរបស់មេធាវីការពារក្តី ហើយបានលើកឡើងសាជាថ្មីនូវទឡ្ហីករណ៍ទាំងឡាយដែលធ្លាប់ត្រូវបានលើកឡើងរួចមកហើយនៅក្នុងសំណើសុំឱ្យបញ្ជាក់អំពីវិសាលភាពនៃសំណុំរឿង[13]។

១២. នៅថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១៦ អង្គជំនុំជម្រះបានបញ្ជាក់ថាខ្លួនមិនត្រូវបានស្នើសុំឱ្យពិនិត្យលើអំពើរំលោភក្រៅអាពាហ៍ពិពាហ៍នោះឡើយ ហើយខ្លួនក៏មិនត្រូវបានអនុញ្ញាតឱ្យពង្រីកការចោទប្រកាន់ប្រឆាំងនឹងជនជាប់ចោទដែរ (“សេចក្តីសម្រេចរងការជំទាស់”)[14]។

## II. ភាពមិនអាចទទួលយកបាននៃបណ្តឹងសាទុក្ខ

១៣. ដើមបណ្តឹងរដ្ឋប្បវេណី បានប្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចរងការជំទាស់ អនុលោមតាមវិធាន ១០៤ ៤) ក) នៃវិធានផ្ទៃក្នុង[15] ដែលចែងថា “*សេចក្តីសម្រេចដែលមានអានុភាពបញ្ចប់កិច្ចដំណើរការនីតិវិធី*” ត្រូវបានបើកផ្លូវឱ្យប្តឹងសាទុក្ខភ្លាមៗ។

១៤. ដោយសារថាកិច្ចដំណើរការនីតិវិធី ទាក់ទងនឹងអំពើរំលោភក្រៅអាពាហ៍ពិពាហ៍ ត្រូវបានបិទបញ្ចប់មុនមានការប្តឹងទៅអង្គជំនុំជម្រះនោះ តាមលក្ខណៈតក្កវិជ្ជា អង្គជំនុំជម្រះ គ្រាន់តែត្រូវកត់សម្គាល់ថា ដំណើរការនីតិវិធីមួយនេះ ពុំរងចាំការសម្រេចពីខ្លួននោះទេ។ ដោយហេតុថាសេចក្តីសម្រេចរងការជំទាស់ ពុំមានអានុភាពបញ្ចប់កិច្ចដំណើរការនីតិវិធីនោះ សេចក្តីសម្រេចនេះ មិនត្រូវបានបើកផ្លូវឱ្យប្តឹងសាទុក្ខភ្លាមៗនោះទេ។

---

ការរំលោភសេពសន្ថវៈ ចុះថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ **E306/7/1** (“ចម្លើយតបទៅនឹងសំណើសុំឱ្យបញ្ជាក់អំពីវិសាលភាពនៃសំណុំរឿង”)។

[13] ការឆ្លើយតបរបស់សហមេធាវីនាំមុខ ទៅនឹងចម្លើយរបស់មេធាវីការពារក្តី ខៀវ សំផន តបសំណើសុំការបញ្ជាក់បំភ្លឺស្តីពីការរំលោភសេពសន្ថវៈ នៅក្រៅអាពាហ៍ពិពាហ៍ដោយបង្ខំ ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១៦ ឯកសារ **E306/7/2**។

[14] សេចក្តីសម្រេចលើសារណារបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី អនុលោមតាមវិធាន ៩២ នៃវិធានផ្ទៃក្នុងស្តីពីការបញ្ជាក់ពីវិសាលភាពនៃសំណុំរឿង ០០២/០២ ទាក់ទងនឹងការចោទប្រកាន់អំពីការរំលោភសេពសន្ថវៈ នៅក្រៅបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E306/7/3** (“សេចក្តីសម្រេចរងការជំទាស់”)។

[15] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ២, ២២-២៣, ៤៩, ៥០-៦៦។

១៥. ផ្ទុយពីអ្វីដែលបានលើកឡើងនៅក្នុងបណ្តឹងសាទុក្ខ[16] អង្គជំនុំជម្រះ មិនត្រូវបានស្នើសុំឲ្យពិនិត្យ និងសម្រេច លើអំពើរំលោភក្រៅអាពាហ៍ពិពាហ៍ឡើយ (១) ហើយសេចក្តីសម្រេចរងការជំទាស់ ពុំមានអានុភាពបញ្ចប់កិច្ចដំណើរការនីតិវិធី ពាក់ព័ន្ធនឹងអំពើនេះទេ (២)។

## ១. អង្គជំនុំជម្រះពុំធ្លាប់ត្រូវបានស្នើសុំឲ្យពិនិត្យលើអំពើរំលោភក្រៅអាពាហ៍ពិពាហ៍ឡើយ

១៦. អង្គជំនុំជម្រះពុំធ្លាប់ត្រូវបានស្នើសុំឲ្យពិនិត្យលើអំពើរំលោភក្រៅអាពាហ៍ពិពាហ៍ឡើយ ដោយសារថា ស.ច.ស បានពិនិត្យរួចរាល់នូវគ្រប់បទចោទប្រកាន់ទាំងអស់ ដែលត្រូវបានស្នើសុំឲ្យខ្លួនពិនិត្យ ដោយ ស.ច.ស បានចេញដីកាលើកលែងការចោទប្រកាន់ ចំពោះអំពើមួយនេះ (ក)។ សេចក្តីសម្រេចនេះ បើកផ្លូវឲ្យប្តឹងឧទ្ធរណ៍ តែពុំត្រូវបានរងបណ្តឹងឡើយ (ខ)។ នៅពេលនេះ មានតែដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ប៉ុណ្ណោះ ដែលលើកឡើងថា អំពើមួយនេះ មិនត្រូវបានលើកលែងការចោទប្រកាន់(គ)។

### ក. ស.ច.ស បានសម្រេចលើកលែងការចោទប្រកាន់ចំពោះអំពើរំលោភសេពសន្ថវៈក្រៅអាពាហ៍ពិពាហ៍

១៧. ដើមបណ្តឹងរដ្ឋប្បវេណី លើកឡើងថា នៅពេលអានសេចក្តីសន្និដ្ឋាននានា ក្នុងដីកាដំណោះស្រាយទាក់ទងនឹងអំពើរំលោភក្រៅអាពាហ៍ពិពាហ៍ ស.ច.ស បានទុកសេរីភាពឲ្យអង្គជំនុំជម្រះ ធ្វើសេចក្តីសន្និដ្ឋានមួយផ្សេងទៀត[17]។ ដើមបណ្តឹងរដ្ឋប្បវេណី យល់ឃើញថា រាល់ការចោទប្រកាន់ផ្នែកអង្គហេតុទាំងអស់ ដែលមានក្នុងដីកាដំណោះស្រាយ ត្រូវបានបញ្ជូនដោយស្វ័យប្រវត្តិ ទៅអង្គជំនុំជម្រះដែលជាអ្នកត្រូវសម្រេចលើការចោទប្រកាន់ទាំងនោះ ហើយក៏ជាអ្នកអាចកំណត់បទចោទសាជាថ្មីទៅតាមឆន្ទានុសិទ្ធិរបស់ខ្លួន ដោយមិនតម្រូវថាត្រូវតែគោរពតាម "មតិយោបល់" ឬ "សំណើ" ដែល ស.ច.ស បានផ្តល់ នៅក្នុងដីកាដំណោះស្រាយនោះទេ[18]។ ដើមបណ្តឹងរដ្ឋប្បវេណី លើកឡើង

---

[16] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៥០-៦៦។

[17] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៥២-៥៨, ៨៩-៩០។

[18] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៧៨, ៨០-៨១, ៩១។

ថា ការណ៍ដែលមានការលើកឡើងអំពីអំពើរំលោភសេពសន្ថវៈក្រៅអាពាហ៍ពិពាហ៍ នៅក្នុងដីកាដំណោះស្រាយ មានន័យបាត់ទៅហើយថា ជនជាប់ចោទត្រូវបានបញ្ជូនទៅជំនុំជម្រះ ចំពោះអំពើនេះ ហើយថា ប្រសិនបើ ស.ច.ស បានសម្រេចលើកលែងការចោទប្រកាន់មែននោះ ស.ច.ស ទំនងជាធ្វើដោយបើកចំហ ក្នុងដីកាមួយដាច់ដោយឡែកពីដីកាដំណោះស្រាយ[19]។

១៨. ដើមបណ្តឹងរដ្ឋប្បវេណី មានការភាន់ច្រឡំទាំងស្រុង។ តាមរយៈការធ្វើសេចក្តីសន្និដ្ឋាន នៅក្នុងដីកាដំណោះស្រាយ ថាអំពើរំលោភសេពសន្ថវៈក្រៅអាពាហ៍ពិពាហ៍ មិនអាចចោទប្រកាន់បានចំពោះជនជាប់ចោទ[20] ស.ច.ស បានសម្រេចលើកលែងការចោទប្រកាន់ ចំពោះអំពើនេះ ក្រោយពីបានផ្តល់សំអាងហេតុរួចមក[21]។ ស.ច.ស មិនត្រូវបានតម្រូវឲ្យចេញជាផ្លូវការ នូវដីកាលើកលែងការចោទប្រកាន់មួយដាច់ដោយឡែក ដើម្បីបញ្ចប់ការពិនិត្យឲ្យអស់នូវរាល់បទចោទប្រកាន់ដែលបានប្តឹងមកខ្លួននោះទេ បើអនុលោមតាមវិធាន ៦៧ ៤) នៃវិធានផ្ទៃក្នុង៖

> *"ដីកាដំណោះស្រាយត្រូវតែមានសំអាងហេតុ។ ដីកានេះ អាចជាដីកាបញ្ជូនរឿងទៅជំនុំជម្រះចំពោះអំពើមួយចំនួន ឬ ប្រឆាំងនឹងបុគ្គលមួយចំនួន និងអាចជាដីកាលើកលែងការចោទប្រកាន់ចំពោះករណីដទៃទៀត"*[22]។

១៩. ដូច្នេះ ដីកាដំណោះស្រាយ (ដែលជាដីកាសម្រាប់បិទបញ្ចប់កិច្ចស៊ើបសួរ) ពុំមែនតម្រូវថាត្រូវតែជាសេចក្តីសម្រេចបញ្ជូន (បញ្ជូនទៅជំនុំជម្រះ) នោះឡើយ។ ដីកាដំណោះស្រាយ ពិតជាអាចមានទាំងសេចក្តីសម្រេចបញ្ជូនទៅជំនុំជម្រះ សម្រាប់អំពើមួយចំនួន និងសេចក្តីសម្រេចលើកលែងការចោទប្រកាន់ ចំពោះអំពើដទៃទៀត។

---

[19] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៥៩, ៨៣, ៨៥។

[20] សូមមើលខាងលើ កថាខណ្ឌ ៣ និងកំណត់សម្គាល់ជើងទំព័រ ៣ (សូមមើលជាពិសេស ផ្នែកនៃដីកាដំណោះស្រាយ ស្តីពីសេចក្តីសន្និដ្ឋានផ្លូវច្បាប់ ពាក់ព័ន្ធនឹងទម្រង់នៃការចូលរួម កថាខណ្ឌ ១៥២១ និងកថាខណ្ឌបន្តបន្ទាប់ ដែលក្នុងនោះ ស.ច.ស ពុំបានទម្លាក់ការទទួលខុសត្រូវលើជនជាប់ចោទ ចំពោះអំពើទាំងនេះឡើយ)។

[21] អនុលោមតាមវិធាន ៦៧ ៣) គ) នៃវិធានផ្ទៃក្នុង ដែលចែងថា ស.ច.ស ចេញដីកាសម្រេចលើកលែងចោទប្រកាន់ នៅពេលយល់ឃើញថា *"ពុំមានភស្តុតាងគ្រប់គ្រាន់ដើម្បីផ្តន្ទាទោសជនត្រូវចោទ"*។ សូមមើលផងដែរ មាត្រា ២៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា។

[22] សូមមើលផងដែរ មាត្រា ២៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ដែលមានខ្លឹមសារដូចគ្នា។

២០. ហេតុដូច្នេះ សេចក្តីសម្រេចលើកលែងការចោទប្រកាន់ ទាក់ទងនឹងអំពើរំលោភសេពសន្ថវៈក្រៅអាពាហ៍ពិពាហ៍ របស់ ស.ច.ស នៅក្នុងដីកាដំណោះស្រាយ ពិតជាមានសុពលភាព[23]។ សេចក្តីសម្រេចតាមផ្លូវតុលាការមួយនេះ ដែលវាលើសពី "មតិយល់ឃើញ" ឬ "សំណើ" ធម្មតា អាចបើកផ្លូវប្តឹងឧទ្ធរណ៍បាន និងជាអាជ្ញាអស់ជំនុំ។

## ខ. សេចក្តីសម្រេចលើកលែងការចោទប្រកាន់ អាចបើកផ្លូវប្តឹងឧទ្ធរណ៍បាន និងជាអាជ្ញាអស់ជំនុំ

២១. អនុលោមតាមវិធាន ៦៧ ៥) នៃវិធានផ្ទៃក្នុង ដីកាដំណោះស្រាយ (ដែលអាចជាដីកាបញ្ជូនរឿងទៅជំនុំជម្រះ ចំពោះអំពើមួយចំនួន និងជាដីកាលើកលែងការចោទប្រកាន់ ចំពោះអំពើដទៃទៀត) "*បើកផ្លូវប្តឹងឧទ្ធរណ៍ ដូចមានចែងក្នុងវិធាន ៧៤*"។ អនុលោមតាមវិធាន ៧៤ ទោះបីថាសហព្រះរាជអាជ្ញា អាចប្តឹងឧទ្ធរណ៍ប្រឆាំងនឹង "*គ្រប់*" សេចក្តីសម្រេចរបស់ ស.ច.ស ក៏ដោយ ក៏ដើមបណ្តឹងរដ្ឋ-ប្បវេណីអាចធ្វើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកា "*លើកលែងការចោទប្រកាន់ ក្នុងករណីដែលសហព្រះរាជអាជ្ញាធ្វើបណ្តឹងឧទ្ធរណ៍ដែរ*" តែប៉ុណ្ណោះ[24]។

២២. ផ្ទុយពីការអះអាងរបស់ដើមបណ្តឹងរដ្ឋប្បវេណី[25] គឺពុំមែនតែដោយសារគ្មានដីកាលើកលែងការចោទប្រកាន់មួយដាច់ដោយឡែកពីដីកាដំណោះស្រាយនោះទេ តែគឺដោយសារថាសហព្រះរាជអាជ្ញា ពុំបានធ្វើបណ្តឹងឧទ្ធរណ៍ទៅវិញទេ ដែលជាឧបសគ្គរាំងដល់ដើមបណ្តឹងរដ្ឋប្បវេណីមិនឲ្យប្តឹងឧទ្ធរណ៍ ប្រឆាំងនឹងសេចក្តីសម្រេចរបស់ ស.ច.ស ដែលមាននៅក្នុងដីកាដំណោះស្រាយ។

---

[23] សេចក្តីសម្រេចនេះ មានលក្ខណៈជាលិខិតតុលាការ ដែលមានអានុភាពជាច្បាប់។ ដីកានេះ "*ត្រូវសម្រេចឲ្យបានច្បាស់លាស់នូវបញ្ហាគតិយុត្តដែលជាកម្មវត្ថុនៃដីកា និងមានផ្ទុកនូវផ្នែកសម្រេចសេចក្តី ដែលអាចដោះស្រាយបញ្ហាអង្គសេចក្តី ឬ បញ្ហានីតិវិធី ដោយបង្កើត កែប្រែ កំណត់ ឬ បញ្ជាក់ អំពីទំនាក់ទំនងផ្នែកច្បាប់ ដែលទាក់ទងនឹងភាគី*" (សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញា ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីវិសាលភាពនៃសំណុំរឿងលេខ ០០២/០១ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១៣ ឯកសារ **E163/5/1/13** កថាខណ្ឌ ៣០)។

[24] វិធាន ៧៤ ២) និង ៧៤ ៤) ច) នៃវិធានផ្ទៃក្នុង។

[25] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៨៤។

២៣. ដើមបណ្តឹងរដ្ឋប្បវេណីលើកឡើងថា ដីកាសម្រេចលើកលែងការចោទប្រកាន់ជាចំហ ពិតជាសំខាន់ខ្លាំងណាស់ នៅក្នុងបរិបទនៃច្បាប់ស៊ីវិល[26] ដែលការអះអាងបែបនេះខុសទាំងស្រុង។ ឧទាហរណ៍ ក្នុងប្រព័ន្ធច្បាប់បារាំង សេចក្តីសម្រេចលើកលែងការចោទប្រកាន់ដោយប្រយោល មិនត្រឹមតែត្រូវបានគេស្គាល់ច្រើននោះទេ តែវាក៏អាចបើកផ្លូវប្តឹងឧទ្ធរណ៍បានថែមទៀតផង[27]។ ម្យ៉ាងវិញទៀត គេគួរកត់សម្គាល់ថា ក្នុងករណីជាក់ស្តែងនេះ ស.ច.ស បានចេញសេចក្តីសម្រេចលើកលែងការចោទប្រកាន់ ដោយចំហ នៅក្នុងដីកាដំណោះស្រាយ ដោយបានបង្ហាញសំអាងហេតុនៃសេចក្តីសម្រេចនេះ។

២៤. គ្មានអ្វីរារាំងសហព្រះរាជអាជ្ញា មិនឲ្យប្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចលើកលែងការចោទប្រកាន់ ចំពោះអំពើរំលោភក្រៅអាពាហ៍ពិពាហ៍ ដែលមាននៅក្នុងដីកាដំណោះស្រាយនោះទេ តែសហព្រះរាជអាជ្ញាបានសម្រេចមិនប្តឹង។ ដើមបណ្តឹងរដ្ឋប្បវេណី សង្កត់ធ្ងន់លើការណ៍ដែលជនជាប់ចោទ ពុំបានប្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចនេះ[28]។ វាជាការពិត។ ជនជាប់ចោទ គ្មានប្រយោជន៍អ្វីដែលត្រូវប្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចលើកលែងការចោទប្រកាន់ដោយផ្នែកៗឡើយ។

២៥. ដោយសារថាសេចក្តីសម្រេចមួយនេះ មិនត្រូវបានរងបណ្តឹងឧទ្ធរណ៍ ក្នុងរយៈពេលកំណត់ សេចក្តីសម្រេចនេះ ជាអាជ្ញាអស់ជំនុំ ក្រោយពីផុតរយៈពេលកំណត់នេះ។ ខុសគ្នាពីសេចក្តីសម្រេចបញ្ជូនរឿងទៅជំនុំជម្រះ ដែលពុំមែនជាអាជ្ញាអស់ជំនុំ ទាក់ទងនឹងអង្គសេចក្តី (ព្រោះថា សេចក្តីសម្រេចបញ្ជូនរឿងទៅជំនុំជម្រះ កម្រិតត្រឹមតែធ្វើការកត់សម្គាល់អំពីអត្ថិភាពនៃបន្ទុកគ្រប់គ្រាន់ សម្រាប់ធ្វើយុត្តិកម្មការបញ្ជូនរឿងទៅតុលាការជំនុំជម្រះ)[29] តាមពិតទៅ សេចក្តីសម្រេចលើកលែងការចោទប្រកាន់ ដែលមានសំអាងហេតុ ជាអាជ្ញាអស់ជំនុំ។ លើកលែងតែក្នុងករណីមានការបើកកិច្ច

---

[26] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៨៧។

[27] ឧទាហរណ៍៖ តុលាការកំពូល សភាព្រហ្មទណ្ឌ ថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ១៩៨៤ បណ្តឹងលេខ ៨៣-៨២៦១៣, តុលាការកំពូល សភាព្រហ្មទណ្ឌ ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០០២ បណ្តឹងលេខ ០១-៨៦៩៥៦ ឯកសារ **E306/7/2.1.2**។

[28] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៩-១០, ៥៩, ៨៥។

[29] ឧទាហរណ៍៖ តុលាការកំពូល សភាព្រហ្មទណ្ឌ ថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ១៩៨៦ បណ្តឹងលេខ ៨៦-៨២០៨៧ និង ៨៦-៨៣៧០៨។

ស៊ើបសួរឡើងវិញ ទាក់ទងនឹងការចោទប្រកាន់ថ្មីៗ តែប៉ុណ្ណោះ អាជ្ញាអស់ជំនុំនេះ ហាមមិនឲ្យមានការចោទប្រកាន់ថ្មី លើអង្គហេតុតែមួយ ទោះជាក្នុងបទចោទព្រហ្មទណ្ឌអ្វីក៏ដោយ[30]។ ការបើកឡើងវិញនូវកិច្ចស៊ើបសួរ ដែលត្រូវបានបិទដោយដីកាលើកលែងការចោទប្រកាន់ គឺជាមធ្យោបាយតែមួយគត់ ដែលអាចត្រឡប់មកពិនិត្យមើលឡើងវិញលើអាជ្ញាអស់ជំនុំ ដែលជាប់មកជាមួយនឹងសេចក្ដីសម្រេចនេះ ហើយដូច្នេះ វាហាមមិនឲ្យតុលាការជំនុំជម្រះ លើកយកឡើងវិញនូវអំពើចោទប្រកាន់នេះ មកពិនិត្យ និងសម្រេច ដោយផ្ទាល់[31]។

២៦. ក្នុងករណីជាក់ស្តែងនេះ សេចក្ដីសម្រេចលើកលែងការចោទប្រកាន់ ចំពោះអំពើរំលោភក្រៅអាពាហ៍ពិពាហ៍ ដែលមាននៅក្នុងដីកាដំណោះស្រាយ ក្លាយជាសេចក្ដីសម្រេចស្ថាពរ ក្រោយផុតរយៈពេលកំណត់នៃការប្ដឹងឧទ្ធរណ៍ គឺមានន័យថា សេចក្ដីសម្រេចនេះចូលជាស្ថាពរ មុនអង្គបុរេជំនុំជម្រះ ចេញសេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍ទាំងឡាយដែលត្រូវបានធ្វើឡើងប្រឆាំងនឹងដីកាដំណោះស្រាយទៅទៀត ហើយដូច្នេះ គឺមុនពេលប្ដឹងទៅអង្គជំនុំជម្រះ។

២៧. ហេតុដូច្នេះ នីតិវិធីពាក់ព័ន្ធនឹងអំពីរំលោភក្រៅអាពាហ៍ពិពាហ៍ បានបញ្ចប់ជាច្រើនសប្ដាហ៍ មុននឹងមានការបញ្ជូនជនជាប់ចោទទៅជំនុំជម្រះ។ បើទោះបីជាមានបញ្ជាក់នៅក្នុងដីកាដំណោះស្រាយក៏

---

[30] វិធាន ៧០ នៃវិធានផ្ទៃក្នុង (“*នៅពេលដែលមានបន្ទុកថ្មីលេចឡើង បន្ទាប់ពីដីកាលើកលែងចោទប្រកាន់របស់សហចៅក្រមស៊ើបអង្កេតបានចូលជាស្ថាពរ ការស៊ើបសួរអាចនឹងត្រូវចាប់ផ្ដើមឡើងវិញដោយសហចៅក្រមស៊ើបអង្កេត តាមគំនិតផ្ដួចផ្ដើមរបស់សហព្រះរាជអាជ្ញា*”), មាត្រា ២៥១ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា (“*ក្រោយពេលដែលដីកាលើកលែងចោទប្រកាន់របស់ចៅក្រមស៊ើបសួរ ឬសាលដីកាលើកលែងចោទប្រកាន់របស់សភាស៊ើបសួរ បានចូលជាស្ថាពរ ប្រសិនមានលេចឡើងបន្ទុកថ្មី ការស៊ើបសួរអាចបើកឡើងវិញ តាមការផ្ដើមគំនិតរបស់ព្រះរាជអាជ្ញា*”), មាត្រា ១៨៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌបារាំង (“*ជនត្រូវចោទ ដែលចៅក្រមស៊ើបសួរ សម្រេចលើកលែងចោទប្រកាន់ មិនអាចត្រូវបានស៊ើបអង្កេត ចំពោះអង្គហេតុតែមួយបានទេ លើកលែងតែក្នុងករណីដែលមានបន្ទុកថ្មីលេចឡើង*”) និង មាត្រា ១៩០ នៃក្រមដដែលនេះ (“*មានតែអយ្យការប៉ុណ្ណោះ ដែលអាចសម្រេចថាតើត្រូវស្នើសុំឲ្យមានការបើកកិច្ចស៊ើបសួរឡើងវិញ ទាក់ទងនឹងបន្ទុកថ្មីដែរឬទេ*”)។ សូមមើលផងដែរ តុលាការកំពូល សភាព្រហ្មទណ្ឌ ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០០៩ បណ្ដឹងលេខ ០៨-៨៥.៣២១, តុលាការកំពូល សភាព្រហ្មទណ្ឌ ថ្ងៃទី ២៤ ខែ មករា ឆ្នាំ ២០០១ បណ្ដឹងលេខ ០០-៨៥.៤០៨។

[31] តុលាការកំពូល សភាព្រហ្មទណ្ឌ ថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ១៩៨០ បណ្ដឹងលេខ ៧៩-៩៥.៣២៦, តុលាការកំពូល សភាព្រហ្មទណ្ឌ ថ្ងៃទី ១៨ ខែ មិថុនា ឆ្នាំ ១៩៩៧ បណ្ដឹងលេខ ៩៦-៨១.៣៧៥។

ដោយ ក៏អំពើនេះមិនស្ថិតក្នុងសេចក្តីសម្រេចបញ្ជូនរឿងទៅជំនុំជម្រះ ដែលបានដាក់ឲ្យអង្គជំនុំជម្រះពិនិត្យ និងសម្រេច នោះដែរ[32]។

## គ. គ្រប់ភាគីបានដឹងច្បាស់ថា មានការសម្រេចលើកលែងការចោទប្រកាន់

២៨. ចាប់តាំងពីមានការប្តឹងទៅអង្គជំនុំជម្រះ នៅឆ្នាំ ២០១១ និងរហូតមកដល់ពេលមានសំណើសុំឲ្យមានការបញ្ជាក់អំពីវិសាលភាពនៃសំណុំរឿង ដោយដើមបណ្តឹងរដ្ឋប្បវេណី នៅឆ្នាំ ២០១៦ ដែលជាដើមចមនៃសេចក្តីសម្រេចរងការចោទប្រកាន់មក ពុំដែលមានភាគីណាមួយ ធ្លាប់បានលើកឡើងថា អំពើរំលោភក្រៅអាពាហ៍ពិពាហ៍ មិនត្រូវបានលើកលែងការចោទប្រកាន់នោះទេ ឬក៏ថា អង្គជំនុំជម្រះ ត្រូវបានប្តឹងឲ្យពិនិត្យលើអំពើនេះដែរ។ ជាក់ស្តែង គឺវាផ្ទុយពីនេះ។

២៩. ដើមបណ្តឹងរដ្ឋប្បវេណី ថែមទាំងជាអ្នកដំបូងគេដែលបានប្រកាសថា (ឆ្នាំ ២០១១) អំពើនេះមិនស្ថិតក្នុងការចោទប្រកាន់ប្រឆាំងនឹងជនជាប់ចោទនោះទេ ហើយថា ស.ច.ស ពុំបានបញ្ជូនការចោទប្រកាន់នេះទៅជំនុំជម្រះនោះឡើយ[33]។ ការណ៍ដែលដើមបណ្តឹងរដ្ឋប្បវេណី បានពន្យល់នៅក្នុងបណ្តឹងឧទ្ធរណ៍ថានៅពេលនោះ ខ្លួន "*មិនបានជំទាស់ថា ការចោទប្រកាន់ពីអង្គហេតុនៃការប្រព្រឹត្តការរំលោភផ្លូវភេទ មិនត្រូវបានរួមបញ្ចូលនៅក្នុងដីកាដំណោះស្រាយ*"[34] ពុំធ្វើឲ្យមានអ្វីប្រែប្រួលនោះទេ ព្រោះថាសារណារបស់ដើមបណ្តឹងរដ្ឋប្បវេណី កាលពីឆ្នាំ ២០១១ បានបង្ហាញថា ដើមបណ្តឹងរដ្ឋប្បវេណីបានយល់យ៉ាងច្បាស់ថា ជនជាប់ចោទពុំត្រូវបានចោទប្រកាន់ចំពោះអំពីរំលោភសេពសន្ថវៈក្រៅអាពាហ៍ពិពាហ៍ នៅចំពោះមុខអង្គជំនុំជម្រះ នោះទេ (នេះជាអ្វីដែលមេធាវីការពារក្តី លោក អៀង សារី បានលើកឡើងកាលពីឆ្នាំ ២០១១ ហើយមេធាវីការពារក្តី លោក ខៀវ សំផន ក៏ធ្វើដូចគ្នាដែរ នៅឆ្នាំ ២០១៦)[35]។ តាមពិតទៅ នៅក្នុងសារណានោះ ដើមបណ្តឹងរដ្ឋប្បវេណី បាន

---

[32] វិធាន ៧៩ នៃវិធានផ្ទៃក្នុង ("*អង្គជំនុំជម្រះសាលាដំបូងទទួលបណ្តឹង ដោយដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេត ឬ តាមសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ*"), វិធាន ៩៨ ២) នៃវិធានផ្ទៃក្នុង ("*សាលក្រមត្រូវសម្រេចត្រឹមតែអង្គហេតុទាំងឡាយណា ដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះប៉ុណ្ណោះ*")។

[33] សូមមើលខាងលើ កថាខណ្ឌ ៦។

[34] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៦១។

[35] សំណើរបស់លោក អៀង សារី សុំអនុញ្ញាតឆ្លើយតប ឬសុំឲ្យមានសវនាការផ្ទាល់មាត់ និងការឆ្លើយតបទៅនឹង "ចម្លើយតប"

សម្ដែងពីភាពមិនសប្បាយចិត្ត ដែលពុំបានប្ដឹងឧទ្ធរណ៍ប្រឆាំងនឹង "*សំអាងហេតុ*" របស់ ស.ច.ស ដោយដើមបណ្ដឹងរដ្ឋប្បវេណីយល់ឃើញថា ជាសំអាងហេតុ "*មានភាពខ្វះចន្លោះ*"[36]។

៣០. សហព្រះរាជអាជ្ញា (ដែលជាអ្នកអាចប្ដឹងឧទ្ធរណ៍ប្រឆាំងនឹងសំអាងហេតុនេះបាន នៅចំពោះមុខអង្គបុរេជំនុំជម្រះ តែសហព្រះរាជអាជ្ញាពុំបានធ្វើ) បានប្រកាសច្រើនលើកច្រើនសា ក្នុងអំឡុងពេលនៃការជំនុំជម្រះថា ជនជាប់ចោទមិនត្រូវបានជំនុំជម្រះចំពោះអំពើរំលោភសេពសន្ថវៈក្រៅអាពាហ៍ពិពាហ៍ឡើយ ដូចដែលដើមបណ្ដឹងរដ្ឋប្បវេណីបានរំពឹក[37]។ លើសពីនេះទៅទៀត សហព្រះរាជអាជ្ញា ក៏ពុំបានចំណាយពេលឆ្លើយតបទៅនឹងសំណើសុំការបញ្ជាក់អំពីវិសាលភាពនៃសំណុំរឿងរបស់ដើមបណ្ដឹងរដ្ឋប្បវេណី នោះទេ។

៣១. មេធាវីការពារក្ដីយល់ឃើញថា ដើមបណ្ដឹងរដ្ឋប្បវេណី អាចបានត្រឹមតែលើកឡើងដោយត្រឹមត្រូវថា សារណារបស់មេធាវីការពារក្ដី E99/3 និង E348 "*ធ្វើឡើងដោយផ្អែកលើមូលដ្ឋានថា ដីកាដំណោះស្រាយ ត្រូវបានប្ដឹងឲ្យពិនិត្យ និងចាត់ការ ចំពោះការចោទប្រកាន់លើអង្គហេតុអំពើរំលោភផ្លូវភេទ*"[38]។ មេធាវីការពារក្ដីពុំដែលគិតថា ដីកាដំណោះស្រាយ ត្រូវបាន "ប្ដឹងឲ្យពិនិត្យ" នោះទេ ខុសគ្នាពីអង្គជំនុំជម្រះ។ បន្ទាប់មកទៀត មេធាវីការពារក្ដីយល់ថា អង្គជំនុំជម្រះត្រូវបានស្នើសុំឲ្យ

---

របស់សហមេធាវីនាំមុខដើមបណ្ដឹងរដ្ឋប្បវេណី ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យកំណត់បទចោទសាជាថ្មី ទាក់ទងនឹងអង្គហេតុនៃអំពើរំលោភសេពសន្ថវៈ ថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ចុះថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០១១ ឯកសារ **E99/1/1** កថាខណ្ឌ ១៦ ("*ដើមបណ្ដឹងរដ្ឋប្បវេណីក៏បានទទួលស្គាល់ដែរថា "អង្គហេតុ" ទាំងនេះត្រូវបានលុបចេញពីដីកាដំណោះស្រាយ*"), ចម្លើយតបទៅនឹងសំណើសុំឲ្យបញ្ជាក់អំពីវិសាលភាពនៃសំណុំរឿង កថាខណ្ឌ ៤ និង ១៣។

[36] ដូច្នេះ វាជាសំអាងហេតុដែលដើមបណ្ដឹងរដ្ឋប្បវេណីបានយល់យ៉ាងច្បាស់ និងថែមទាំងបានតវ៉ាទៀតផង កាលពីឆ្នាំ ២០១១ ខណៈដែលនៅពេលនេះ ដើមបណ្ដឹងរដ្ឋប្បវេណីនិយាយថាខ្លួនមិនយល់ទៅវិញ ដោយសារថាគ្មានដីកាលើកលែងចោទប្រកាន់ផ្លូវការ (បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ៨៤) តែទន្ទឹមគ្នានោះ ដើមបណ្ដឹងរដ្ឋប្បវេណីទទួលស្គាល់ថា សហចៅក្រមស៊ើបអង្កេត "*ពុំបានផ្ដល់ទស្សនៈ និងការពិចារណា*" (បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ៨០)។

[37] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ១៥-១៦, សូមមើលផងដែរ ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹង "សំណើរបស់ ខៀវ សំផន សុំឲ្យមានការតទល់គ្នារវាងដើមបណ្ដឹងរដ្ឋប្បវេណី សយ សែន ជាមួយនឹងសាក្សី ស្រី ថន និងដើមបណ្ដឹងរដ្ឋប្បវេណី សូត្រ សាំង និងស្នើសុំឯកសារថតចម្លងនៃការស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី សយ សែន នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១៥ ឯកសារ **E348/1** កថាខណ្ឌ ៤ កំណត់សម្គាល់ជើងទំព័រ ១៤ (យោងទៅកថាខណ្ឌ ៨២៦-៨២៧, ១១៨១, ១៤២៨ និង ១៤២៩ នៃដីកាដំណោះស្រាយ)។

[38] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ៨៦។

ពិនិត្យ និងសម្រេចលើអំពើរំលោភសេពសន្ថវៈ តែនៅក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ប៉ុណ្ណោះ។ ជាចុងក្រោយ គ្មានអ្វីនៅក្នុងសារណា E99/3 និង E348 អាចឲ្យគេគិតបានថា មេធាវីការពារក្តីបានឈរលើគោលការណ៍ថា លោក ខៀវ សំផន ត្រូវបានបញ្ជូនទៅជំនុំជម្រះ ចំពោះអំពើរំលោភសេពសន្ថវៈផ្សេងៗទៀត ក្រៅបរិបទនៃការរៀបអាពាហ៍ពិពាហ៍នោះឡើយ។ សារណាទីមួយ (ឯកសារ E99/3) គ្រាន់តែលើកឡើងថា អង្គបុរេជំនុំជម្រះ បានសម្រេចលើបញ្ហាច្បាប់ដែលត្រូវយកមកអនុវត្ត និងពុំមែនលើការកំណត់បទចោទសាជាថ្មី ចំពោះអំពើរំលោភសេពសន្ថវៈ នោះទេ ដើម្បីបង្ហាញឲ្យឃើញថា សំណើសុំកំណត់បទចោទសាឡើងវិញរបស់សហព្រះរាជអាជ្ញា មិនអាចទទួលយកបាន (ព្រោះថា តាមពិតទៅ សំណើនេះផ្តោតលើបញ្ហាយុត្តាធិការ ហើយដូច្នេះសំណើនេះ គឺជាអញ្ញត្រកម្មបន្លំក្លែក)។ ក្នុងសារណាទីពីរ (ឯកសារ E348) មេធាវីការពារក្តី គ្រាន់តែលើកឡើងពីភាពផ្ទុយគ្នារវាងចម្លើយបុគ្គលផ្សេងៗ ទាក់ទងនឹងចំណុចជាច្រើន (ក្នុងនោះមានអំពើរំលោភសេពសន្ថវៈ) ដែលធ្វើឲ្យប៉ះពាល់ដល់ភាពជឿទុកចិត្តបានរបស់ពួកគេ ដើម្បីធ្វើយុត្តិកម្មសំណើសុំឲ្យមានការតទល់គ្នារវាងបុគ្គលទាំងនោះ។

៣២. សរុបរួមមក ស.ច.ស បានសម្រេចលើកលែងការចោទប្រកាន់ ចំពោះអំពើរំលោភសេពសន្ថវៈក្រៅអាពាហ៍ពិពាហ៍។ សេចក្តីសម្រេចនេះ ចូលជាស្ថាពរ មុននឹងមានការប្តឹងទៅអង្គជំនុំជម្រះ។ ដូចគ្នានឹងភាគីទាំងអស់ដែរ អង្គជំនុំជម្រះបានយល់យ៉ាងច្បាស់អំពីចំណុចនេះ។

## ២. សេចក្តីសម្រេចរងការជំទាស់ គ្មានអានុភាពបញ្ចប់កិច្ចដំណើរការនីតិវិធី

៣៣. ដើមបណ្តឹងរដ្ឋប្បវេណី យល់ឃើញថា សេចក្តីសម្រេចរងការជំទាស់ មានអានុភាពបញ្ចប់កិច្ចដំណើរការនីតិវិធី ព្រោះថា អង្គជំនុំជម្រះយល់ឃើញថាអង្គហេតុចោទប្រកាន់ទាំងនេះ មិនស្ថិតក្នុងបណ្តឹងដាក់មកកាន់ខ្លួននោះទេ។ អង្គជំនុំជម្រះ នៅស្ងៀមមិនព្រមសម្រេចលើបណ្តឹងដាក់ជូនខ្លួន ហើយបានសម្រេចលើបញ្ហាកំណត់បទចោទសាជាថ្មីមួយចំនួន “*នៅក្រៅប្រធានបទ*”[39]។

---

[39] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៦២-៦៥។ សូមមើលផងដែរ កថាខណ្ឌ ៧៣-៧៦។

៣៤. បើទោះជាមេធាវីការពារក្តី មើលពុំឃើញពីរបៀបដែលទឡ្ហីករណ៍ទាំងនេះអាចបង្ហាញឲ្យឃើញថា សេចក្តីសម្រេចរងការជំទាស់ មានអានុភាពបញ្ចប់កិច្ចដំណើរការនីតិវិធី ពាក់ព័ន្ធនឹងអង្គហេតុទាំងនេះក៏ដោយ ក៏ទោះយ៉ាងណាក៏ដោយ ក៏ទឡ្ហីករណ៍ទាំងនេះ ពុំត្រឹមត្រូវនោះដែរ។ អង្គជំនុំជម្រះ បានធ្វើឲ្យគេយល់ថា អំពើរំលោភក្រៅអាពាហ៍ពិពាហ៍ មិនស្ថិតក្នុងបណ្តឹងដាក់មកខ្លួនពិនិត្យទេ។ អង្គជំនុំជម្រះ បានសម្រេចយ៉ាងច្បាស់ ដោយបានកត់សម្គាល់ (សាជាថ្មី) ថាខ្លួនមិនត្រូវបានប្តឹងឲ្យពិនិត្យលើអង្គហេតុទាំងនេះទេ។ ទោះបីជាអង្គជំនុំជម្រះបានសម្រេចលើបញ្ហាមួយចំនួនស្តីពីការកំណត់បទចោទសាជាថ្មី នៅក្រៅប្រធានបទក៏ដោយ ក៏អង្គជំនុំជម្រះធ្វើនេះ គឺដើម្បីឆ្លើយតបទៅនឹងទឡ្ហីករណ៍ក្រៅប្រធានបទទាំងឡាយ ដែលត្រូវបានលើកឡើងនៅក្នុងសំណើសុំការបញ្ជាក់អំពីវិសាលភាពនៃសំណុំរឿង(ដែលត្រូវបានលើកឡើងវិញនៅក្នុងបណ្តឹងឧទ្ធរណ៍)។

៣៥. ដូចដែលដើមបណ្តឹងរដ្ឋប្បវេណី[40]បានបញ្ជាក់ អង្គជំនុំជម្រះមិនអាចកំណត់បទចោទឡើងវិញចំពោះអំពើដែលមិនត្រូវបានប្តឹងមកខ្លួននោះទេ។ នេះគឺជាអ្វីដែលអង្គជំនុំជម្រះ ធ្លាប់បានរំឭកឡើងវិញ នៅក្នុងសេចក្តីសម្រេចរងការជំទាស់[41] មុននឹងអង្គជំនុំជម្រះលើកឡើងនូវបទប្បញ្ញត្តិពាក់ព័ន្ធនានា នៅក្នុងដីកាដំណោះស្រាយ និងបន្ទាប់មក ប្រកាសថា៖

> "*ផ្អែកលើសំអាងហេតុទាំងនេះ បទល្មើសរំលោភសេពសន្ថវៈ ដែលជនជាប់ចោទត្រូវបានចោទប្រកាន់ ក្នុងផ្នែកនៃដីកាដំណោះស្រាយ មិនត្រូវបានរួមបញ្ចូលការរំលោភសេពសន្ថវៈនៅក្រៅបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ នៅក្នុងមន្ទីរសន្តិសុខ និងសហករណ៍នោះឡើយ។ គ្មានបទល្មើសណាផ្សេងទៀត បានផ្អែកលើអង្គហេតុនៃការរំលោភសេពសន្ថវៈនៅក្រៅបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំឡើយ។ ការបកស្រាយនេះ ត្រូវបានបញ្ជាក់បន្ថែមដោយទម្រង់នានានៃការទទួលខុសត្រូវ ដែលមានក្នុងដីកាដំណោះស្រាយដែលគ្រាន់តែពិចារណាលើការរំលោភសេពសន្ថវៈក្នុងបរិបទនៃអាពាហ៍ពិពាហ៍ដោយបង្ខំប៉ុណ្ណោះ*"[42]។

---

[40] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៧៦។

[41] សេចក្តីសម្រេចរងការជំទាស់ កថាខណ្ឌ ១១ (*"[...] មុនធ្វើការសម្រេចកំណត់បទចោទឡើងវិញ អង្គជំនុំជម្រះត្រូវធ្វើការពិចារណាលើអង្គហេតុជាក់លាក់នានា ដែលជាមូលដ្ឋានដែលជនជាប់ចោទ ត្រូវបានចោទប្រកាន់ជាផ្លូវការ*")។

[42] សេចក្តីសម្រេចរងការជំទាស់ កថាខណ្ឌ ១៥។

៣៦. អង្គជំនុំជម្រះបានកត់សម្គាល់យ៉ាងច្បាស់ពីការលើកលែងការចោទប្រកាន់របស់ ស.ច.ស ចំពោះអំពើរំលោភក្រៅអាពាហ៍ពិពាហ៍ ហើយអង្គជំនុំជម្រះ មិនត្រូវបានស្នើសុំឲ្យពិនិត្យលើអំពើនេះ នៅក្នុងបណ្ដឹងដាក់មកខ្លួននោះឡើយ។ នៅក្រោយមកបន្តិច អង្គជំនុំជម្រះ បានប្រកាសយ៉ាងច្បាស់ថា៖

> "*នៅដំណាក់កាលជំនុំជម្រះ ផ្ទុយពីការសន្និដ្ឋានរបស់សហមេធាវីនាំមុខ ដីកាបង្គាប់ឲ្យបំបែកកិច្ចដំណើរការនីតិវិធីបន្ថែម មិនមានដាក់បញ្ចូលការចោទប្រកាន់លើការរំលោភសេពសន្ថវៈនៅក្រៅបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ <u>ដែលមិនត្រូវបានចោទប្រកាន់ក្នុងដីកាដំណោះស្រាយនោះឡើយ</u>។ ភាពស៊ីសង្វាក់នៃជំហររបស់អង្គជំនុំជម្រះសាលាដំបូង បានបង្ហាញនៅក្នុងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះពីរួចមកហើយ*" (យើងជាអ្នកគូសបន្ទាត់ពីក្រោម)[43]។
>
> (...)
>
> "*នៅថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០១៥ អង្គជំនុំជម្រះសាលាដំបូង <u>បានបញ្ជាក់ម្ដងទៀតថា ការចោទប្រកាន់នៃការរំលោភសេពសន្ថវៈក្រៅការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ មិនមានរួមបញ្ចូលនៅក្នុងដីកាដំណោះស្រាយឡើយ</u>*" (យើងជាអ្នកគូសបន្ទាត់ពីក្រោម)[44]។

៣៧. ដូចគ្នានេះដែរ នៅពេលដែលអង្គជំនុំជម្រះ ពិចារណាឃើញថា បើខ្លួនសម្រេចឯកភាពតាមសំណើរបស់ដើមបណ្ដឹងរដ្ឋប្បវេណី គឺមានន័យថាខ្លួនពង្រីកការចោទប្រកាន់[45] អង្គជំនុំជម្រះបានកត់សម្គាល់ថា ការចោទប្រកាន់ដែលចោទជាបញ្ហានេះ មិនស្ថិតក្នុងបណ្ដឹងដាក់មកខ្លួននោះទេ។ លើសពីនេះទៀត អង្គជំនុំជម្រះរំឭកថា ខ្លួនមិនអាចធ្វើលើសពីដែនអំណាចដែលវិធាន ៩៨ ២) នៃវិធានផ្ទៃក្នុង ប្រគល់ជូនខ្លួនបានទេ[46]។ វិធានមួយនេះ កំណត់អំពីវិសាលភាពនៃបណ្ដឹងដាក់មកអង្គជំនុំជម្រះសាលាដំបូង៖ "*សាលក្រមត្រូវសម្រេចត្រឹមតែអង្គហេតុទាំងឡាយណា ដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះប៉ុណ្ណោះ*"។

---

[43] សេចក្ដីសម្រេចរងការជំទាស់ កថាខណ្ឌ ១៧។

[44] សេចក្ដីសម្រេចរងការជំទាស់ កថាខណ្ឌ ១៨។

[45] សេចក្ដីសម្រេចរងការជំទាស់ កថាខណ្ឌ ១៧, ១៨ និង ១៩។

[46] សេចក្ដីសម្រេចរងការជំទាស់ កថាខណ្ឌ ១៩។

៣៨. អាស្រ័យដូចនេះ គេមិនអាចចាត់ទុកថា អង្គជំនុំជម្រះនៅស្ងៀមមិនចាត់ការលើបណ្តឹងដាក់មកខ្លួនបានទេ។ វាច្បាស់ណាស់ថា អង្គជំនុំជម្រះបានត្រឹមតែធ្វើការកត់សម្គាល់ថា ខ្លួនមិនត្រូវបានស្នើសុំឲ្យពិនិត្យលើអង្គហេតុទាំងឡាយដែលដំណើរការនីតិវិធីបានបិទបញ្ចប់ មុនពេលប្តឹងមកខ្លួននោះទេ។ អង្គជំនុំជម្រះ បានកត់សម្គាល់បែបនេះ ក្រោយពីមានសេចក្តីសម្រេចលើកលែងការចោទប្រកាន់របស់ ស.ច.ស ដែលជាអាជ្ញាអស់ជំនុំ។

៣៩. បើទោះជាមេធាវីការពារក្តី ត្រូវឯកភាពជាមួយដើមបណ្តឹងរដ្ឋប្បវេណី ថាមានបញ្ហា នៅពេលដែលអង្គជំនុំជម្រះយល់ឃើញថា អង្គហេតុដែលមិនត្រូវបានប្តឹងមកខ្លួន អាចមានភាពពាក់ព័ន្ធក៏ដោយ[47] ក៏បញ្ហានេះ (ដែលកើតឡើងដដែលៗ ចំពោះអង្គជំនុំជម្រះ បើទោះបីវាពុំមែនតែងតែជាបញ្ហាសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីក៏ដោយ)[48] មិនអាចត្រូវបានលើកឡើងនៅក្នុងក្របខណ្ឌនៃបណ្តឹងឧទ្ធរណ៍ភ្លាមៗបានឡើយ ព្រោះវាពុំមែនជាបញ្ហាដែលមានអានុភាពបញ្ចប់កិច្ចដំណើរការនីតិវិធី ។

## <u>**សេចក្តីសន្និដ្ឋាន**</u>

៤០. សេចក្តីសម្រេចរងការជំទាស់ មិនមានអានុភាពបញ្ចប់កិច្ចដំណើរការនីតិវិធី ពាក់ព័ន្ធនឹងការរំលោភសេពសន្ថវៈក្រៅអាពាហ៍ពិពាហ៍។ សេចក្តីសម្រេចនេះ បានត្រឹមតែកត់សម្គាល់ថា ដំណើរការនីតិវិធីនេះ បានបិទបញ្ចប់ នៅពេលស៊ើបអង្កេត ហើយអង្គជំនុំជម្រះ មិនត្រូវបានស្នើសុំឲ្យពិនិត្យ និងសម្រេចលើអំពើនេះទេ។ អាស្រ័យហេតុនេះ បណ្តឹងឧទ្ធរណ៍ មិនអាចត្រូវទទួលយកបានឡើយ។

---

[47] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៦៦ និង ៧៧។

[48] សូមមើល ឧទាហរណ៍ សេចក្តីថ្លែងរបស់មេធាវី GUIRAUD ពាក់ព័ន្ធនឹងអង្គហេតុទាក់ទងនឹងព្រៃស ដែលត្រូវបានដកចេញពីវិសាលភាពនៃសំណុំរឿង ០០២/០២ ហើយដូច្នេះ ក៏ត្រូវដកចេញពីបណ្តឹងដាក់ជូនអង្គជំនុំជម្រះដូចគ្នា៖ ប្រតិចារឹកសវនាការថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ២០១៦ ឯកសារ **E1/430.1** ទំព័រ ៣៥ បន្ទាត់ ១០-១៣ មុនម៉ោង [១១.២៨.៤៥]៖ *"តាមការយល់របស់យើងខ្ញុំ ជនជាប់ចោទដែលបានបញ្ជូនមកទីនេះ គឺមិនមែនពាក់ព័ន្ធទៅនឹងព្រៃសទេ នេះជាអ្វីដែលយើងបានយល់ពីសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ ទាក់ទងនឹងការបំបែកកិច្ចដំណើរការនីតិវិធី ។ ក៏ប៉ុន្តែ ទោះជាយ៉ាងណាក៏ដោយ ព្រៃសប្រហែលជាអាចយកមកពិភាក្សាគ្នាបាន ជាលក្ខណៈទូទៅ ពាក់ព័ន្ធទៅនឹង ស-២៥"*។

៤១. **ផ្អែកតាមសំអាងហេតុនេះ** មេធាវីការពារក្តីស្នើសុំឲ្យអង្គជំនុំជម្រះតុលាការកំពូលមេត្តា**ប្រកាស** ថា បណ្តឹងឧទ្ធរណ៍នេះ មិនអាចទទួលយកបានទេ។

| | | | |
|---|---|---|---|
| | មេធាវី គង់ សំអុន | រាជធានីភ្នំពេញ | |
| | មេធាវី Anta GUISSÉ | រាជធានីភ្នំពេញ | |